ប្រវែងពីមុខចៀរមកចានត្រងជ័រមានប្រវែង ៣៥ស.ម ។ ចានអាចដាក់នៅកំពស់អតិបរិមា ១៧០ស.ម ពីដី ទោះបីមុខចៀរជ័រនៅខ្ពស់ដល់ណាក៏ដោយ ។ នៅចន្លោះពីមុខចៀរមកស្លាបព្រាដែលមានប្រវែង ២០ស.ម គេឆូតចង្អូរធ្វើជាទបង្ហូរជ័រ ។

**៥. ការបើកមុខចៀរជ័រដំបូង:** មុននឹងចាប់ផ្តើមដំណើរការចៀរជ័រដំបូង គេត្រូវបើកមុខចៀរចំនួន៣ពន្លាកជាមុនសិន ដោយចៀរតាមលំនាំខ្នាតមុំចំណោតមុខចៀរដែលបានរៀបរាប់នៅចំនុចទី ៣ ខាងលើនិងអនុវត្តតាមជំហានដូចខាងក្រោម:



ពន្លាកទី១: ចៀរស្តើរៗតាមគំរូចំណោតមុខចៀរ ។

ពន្លាកទី២: ចៀរតាមលំនាំនៃពន្លាកទី១អោយបានជ្រៅជាងពន្លាកទី១ បន្តិច ។

ពន្លាកទី៣: យកពន្លាកមកចៀររុញអោយដល់ជម្រៅតាមបទដ្ឋានដែលបានកំនត់គឺទុក ១ម.ម ពីស្រទាប់ Cambium ។





**វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា**

អាសយដ្ឋាន : អគារលេខ ៥ មហាវិថី ប៉ែន នុត (២៨៩)
សង្កាត់បឹងកក់ ១ ខណ្ឌទួលគោក
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ឬ ប្រអប់សំបុត្រលេខ ១៣៣៧
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ : (៨៥៥) ២៣ ៨៨២ ៨៣០

ទូរសារ : (៨៥៥) ២៣ ៨៨២ ៨៣១

អ៊ីមែល : crri@camnet.com.kh



ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

*មគ្គុទេសក៍បច្ចេកទេស ២០០៨/០២*


# របៀបបើកមុខចៀរដំបូង




ការបោះពុម្ពផ្សាយរបស់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា
ការិយាល័យសរីរវិទ្យា-អាជីវកម្ម

**១. សេចក្តីផ្តើមៈ** សម្បកកៅស៊ូមានសារៈសំខាន់ណាស់ចំពោះដំណើរការចៀរជ័រ។ អ្នកដាំកៅស៊ូត្រូវយកចិត្តទុកដាក់លើរបៀបបើកមុខចៀរជ័រដំបូង។ ធនធានសេដ្ឋកិច្ចនៃដំណាំកៅស៊ូ គឺស្ថិតលើដើម និងសម្បកកៅស៊ូ។ បើការបើកមុខចៀរជ័រដំបូងមិនបានរៀបចំទៅតាមលក្ខណៈបច្ចេកទេសត្រឹមត្រូវទេ ផលិតកម្មកៅស៊ូនឹងថយចុះ។ ដូច្នេះម្ចាស់ចំការកៅស៊ូ ឬអ្នកទទួលខុសត្រូវ មានភារកិច្ចក្នុងការរៀបចំរបៀបបើកមុខចៀរជ័រដំបូងអោយបានល្អទៅតាមបច្ចេកទេស ដែលបានកំនត់ដោយវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា។

**២. ការកំណត់ទំហំដើមចៀរៈ** ដើមកៅស៊ូបំបៅអាចបើកមុខចៀរនៅទំហំ៥០ស.ម(វាស់នៅកំពស់១០០ស.មពីដី)។

**៣. របៀបបង្កើតមុខចៀរជ័រៈ** ដំបូងត្រូវវាស់និងជ្រើសរើសដើម



*ការដៅចំណុចសំគាល់ដើមសំរាប់បើកមុខចៀរ*

កៅស៊ូដែលមានទំហំ ៥០ស.ម នៅកំពស់ ១០០ស.ម ពីដី និងមានចំនួនដើមទំហំដូចខាងលើស្មើ៧០% នៃចំនួនដើមទាំងអស់ក្នុងមួយហិកតា។ បន្ទាប់មកគេដៅចំនុចសំគាល់ពណ៌ក្រហមលើដើមទំហំខាងលើនៅកំពស់ ១៧០ស.ម ពីដី រួចគូសបន្ទាត់ឈរពីរឈមគ្នានៅលើដើមដែលមានចំនុចក្រហមសំគាល់នោះ ដើម្បីចែកផ្ទាំងមុខចៀរ ដោយប្រើបន្ទាត់ឈើដែលមានប្រវែងពីរម៉ែត្រ។



*ការចែកផ្ទាំងសម្បកជាពីរ*

គេដាក់ម៉ែត្រអឹបជាប់ ហើយបញ្ឈរស្របនឹងស្ថានភាពដើមអោយចំពាក់កណ្តាល រួចឆូតអោយមុតជ្រៅបន្តិច។ បន្ទាប់មកគេយកឧបករណ៍គំរូមុខចៀរ(ទង់ជ័យ) ធ្វើអំពីឈើសងខាង និងភ្ជាប់តួកណ្តាលដោយដែកបន្ទះ មកដាក់ភ្ជាប់ទៅនឹងដើមកៅស៊ូរួចគូស ដើម្បីបង្កើតមុខចៀរដែលមានមុំ ៣០អង្សា (ដើមបំបៅ)។ ទន្ទឹមនឹងនេះ គេត្រូវក្រិតសម្បកសំរាប់ការចៀររយៈពេល ១ខែ, ៣ខែ និងមួយឆ្នាំ។

ការចំណាយសម្បកចំពោះដើមកៅស៊ូទើបបើកមុខចៀរថ្មី គឺស្មើ ១២ស.ម រីឯដើមកៅស៊ូមធ្យមស្មើ ១៣ស.ម និងដើមកៅស៊ូចាស់ស្មើ ១៥ស.ម ទៅ ២០ស.ម ក្នុងមួយឆ្នាំ។



*ឧបករណ៍គំរូមុខចៀរ*



*ការក្រិតសម្បកសម្រាប់ចៀរ*

**៤. កំពស់មុខចៀរៈ** គេបើកមុខចៀរជ័រនៅកំពស់ ១៣០ស.ម ពីដី (ដើមដាំដោយបំបៅ)។



*ការបំពាក់ស្លាបព្រា (ទបង្ហូរជ័រ) និងចានត្រងជ័រ*